**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*******

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៤៧០១ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ " គំពង់ឬស្សី "

## ស្ថិតនៅក្នុង ឃុំ ជីរោទិ៍១ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ជីរោទិ៍១ ស្រុក ត្បូងឃ្មុំ ចុះថ្ងៃទី ១១ សីហា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

# សំរេច

**ប្រការ ១ :** អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " គំពង់ឬស្សី " ស្ថិតនៅក្នុង ឃុំ ជីរោទិ៍១ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ចាម និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០០៦

**បណ្ឌិត ក៏ុល ផែង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលា ខេត្ត កំពង់ចាម "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ទា.មចទ

Ith Chetha/NewSchool doc